- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- យោងលិខិតរបស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យចក-ដីរេល ចុះថ្ងៃទី ០១ កុម្ភៈ ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និង អភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតប្តូរឈ្មោះអនុវិទ្យាល័យចក-ដីរេល ទៅជា «អនុវិទ្យាល័យ **ហេង សំរិន**» ចាប់ពីឆ្នាំសិក្សា ១៩៩៥-៩៦ តទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា -ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកំពង់ចាម និង នាយកអនុវិទ្យាល័យ **ហេង សំរិន** មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តុល លោះ**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៣៩៨ អយក.ប្រក**

**ស្តីពីការប្តូរឈ្មោះវិទ្យាល័យខ្សាច់កណ្តាលទៅជា**

**«វិទ្យាល័យ ហ៊ុន សែន » ខ្សាច់កណ្ដាល**

**ស្ថិតនៅក្នុងស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្ដីពី ប្រព័ន្ធអប់រំចំណេះទូទៅ
- យោងលិខិតរបស់នាយកអនុវិទ្យាល័យខ្សាច់កណ្ដាល ០១០ វិ.ខ្ស.ក ចុះថ្ងៃទី ០៥ កុម្ភៈ ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និង អភិបាលខេត្តកណ្ដាល
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតប្ដូរឈ្មោះអនុវិទ្យាល័យខ្សាច់កណ្ដាលទៅជា «អនុវិទ្យាល័យ **ហ៊ុន សែន ខ្សាច់កណ្ដាល** » ចាប់ពីឆ្នាំសិក្សា ១៩៩៥-៩៦ តទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជា និរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា -ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកណ្ដាល និង នាយកវិទ្យាល័យ **ហ៊ុន សែន ខ្សាច់កណ្ដាល** មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តូច ឡោះ**

* * *